Theology on the Web.org.uk

Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

HONEYCOMB 2/3 (July 2001): 19–30



# MISSIONARY-NATIONAL RELATIONSHIPS

Stages of growth

*Wes LINDQUIST*

## Introduction

Whenever we talk about working together we are talking about relationships. In John 17 Jesus taught that the world would know we are His disciples by our relationships. Cambodian nationals, Do you have a good relationship with the missionaries with whom you are working? Missionaries, Do you have a good relationship with the nationals with whom you are working? The goal of this article is to stimulate better relationships between us.

## The Flow of Partnership

**Relationship**—As the following graphic illustrates, all partnerships are built on *relationship*. This is the foundation of all strong churches, NGO's, or any other type of organization. Without strong relationships our partnerships will be weak and short-lived.

**Purpose**—Once strong relationships have been built we need to have a *purpose*. A relationship without purpose is simply a group of friends. For a partnership we must have a mutually-agreed purpose—something we both want to accomplish.




**Strategy**—Once our relationship has an agreed-upon purpose, we then need to determine a *strategy*. How are we going to accomplish our purpose? This is where experience and training begin to show a great profit.

**Resources**—As Christians our next step in our relationship is to prayerfully determine the *resources* needed to complete our strategy and fulfill our purpose. In the world we often start the process by looking at our resources: "How much money do we have?" But as Christians we need to seek God's purpose and strategy first. Then by faith we pray the resources in.

**Work**—Finally, the partnership we have built upon strong relationships, mutually-defined purpose, wise strategy, and calculated resource management, can begin to *work* together.

The result of a partnership built on strong relationships is the ability to do great works for God. Whether in the church, an NGO, or any other Christian organization, the strength of the organization is found in the strength of their relationships.

## The Centrality of Relationships

The remainder of this article will focus on one element of the above model. The most important and yet most fragile component is our *relationships*. Brothers and sisters, we can have the best purpose, the finest strategies, and all the resources imaginable, but our partnerships and work will come to nothing *if our relationships crumble.* We must place a higher priority on our relationships than on our work. Jesus didn't die for any of our projects; he died for people. We must give more care and attention to people than to the work. That priority begins with those with whom we work, and not just the disadvantaged or hurting sinners our projects so often target.

# RELATIONSHIPS ARE OUR PRIORITY

- **Jesus didn't die for your projects**
- **Jesus died so we might have good relationships**



Winter uses a four-stage model for working through missionary–national church relationships.[1] The great value in his model is its recognition that all relationships must change and

---

[1]Ralph D. Winter and Steven C. Hawthorne, eds., *Perspectives on the World Christian Movement* (Pasadena: William Carey Library, 1981).

develop. This is a sign of growth and health. Yet there will always be stress associated with change. The change required to move from one stage to another on this model causes us great stress. If we learn these stages of relationship, we can better understand one another and better partner together. It will also help us find a good path through the stressful changes of growth and development.

## Missionary – National Relationship
## Four Stages of Development

- **Stage 1: Pioneer Stage**
  - **First contact with a people group. Evangelism and relief work are some of the principal tools used.**
- **Stage 2: Paternal Stage**
  - **Expatriates train national leadership. The establishment of Bible Schools and assorted other training methods take shape. Relief is moving into development.**
- **Stage 3 Partnership Stage**
  - **National leaders work as equals with expatriates. Turning over control and projects to national leadership, with expatriates acting as mentors.**
- **Stage 4 Participation Stage**
  - **Expatriates are no longer equal partners, but only participate by invitation. Specialized and highly trained missionaries are needed to support the national church in areas like Christian media production and advanced theological training.**




As a missionary myself, I will begin by talking about the role of the missionary. It is an ever-evolving role, much like that of a teacher who teaches a student, and then trains that student to become a teacher, and then finally becomes an employee in his student's school.

Sometimes we use the analogy of a parent and child to describe this growing relationship. Missionaries must not forever maintain a dominant role over the local work, nor should they relinquish the local work too quickly. As with all living things, there is a natural process of growth and development. No parent wants to find himself or herself feeding and bathing a twenty-year-

old child. Missionary relationships should mirror this natural pattern.

Understanding this model allows us to see that our roles and relationships will naturally change over time. As we progress toward a mature national church we will move through each of these four stages. The important fact to remember is that each organization and denomination is on a different pace. There is no "right" method nor is there a "uniform speed" that all relationships will follow. As with our children, some grow up faster than others.

One word of caution—2 Cor 10:12 warns us of the "foolishness" of comparing ourselves among ourselves. One of the most dangerous activities in which we can engage is to compare the way different missionaries and nationals develop their relationships. As with all living things, growth takes place according to specific conditions of proper food, water, nurture, and care. The "soil" or personality of the people involved plays a large part in growth. I am weary of the sweeping generalizations like, "All missionaries are colonial and domineering," or "All nationals are Biblically uneducated and greedy for money and power." There is no basis to make such statements, and genuine relationships will never form in such a hostile environment.

**Pioneer Stage**

The fact is there are times when a strong visionary pioneer is needed. Pioneers tend to have strong, domineering personalities. These people will let nothing stand in the way of bringing the light of the Gospel to souls trapped in darkness. These are strong people with strong opinions. Look at them one moment and you can see them sacrificing their freedoms and rights for others; look at them another moment and you see them crashing headfirst into conflict and poor decisions. These people are like the mighty water buffalo—if their strength is guided in the right direction they can do great benefit. But should their strength be misguided they cause great harm.

Currently, only 0.6% of Cambodia's population believes in Christ. To argue we don't need pioneer missionaries ignores this fact. To my knowledge, nearly every one of the twenty-one

provinces has at least one Christian home fellowship or church, and all four city principalities have a church. But how many of the 173 provincial districts or how many of the 36,000 villages have a Christian witness? The vast majority do not have any witness for Christ at all! This is a country that is desperately in need of pioneer missionaries. I would even dare to challenge the budding national church to focus its resources on pioneering new districts and villages for Christ too.

## Pioneer Stage

**Positives:**

- ✓ **Strong independent personality**
- ✓ **Will sacrifice greatly to see others hear the gospel**
- ✓ **Self starters**
- ✓ **Little conflict since there is no one else to argue with**

**Negatives:**

- ✓ **Strong independent personality**
- ✓ **Tend to have blind spots**
- ✓ **Confrontational**



mission

In the present pioneering stage of missions work in Cambodia, many foreigners are confused by arguments such as, "The colonial days of pioneering are over. Now, we need to empower and equip nationals." Another argument runs, "Nationals can do it with better language and cultural sensitivity and certainly with far less cost." Yet those who argue this way fail to realize that such logic comes from nations with more than two hundred years of missions history. The current trend across the world is that "Developing World" or "Second World" nations are beginning to send missionaries.

Here in Cambodia we see fruit produced by Filipino, Korean, and Thai missionaries. These sending countries have

enjoyed more than 150, 100, and 80 years of national church development respectively. Let's compare these countries to Cambodia. Yes, Cambodia had its first Protestant missionaries nearly eighty years ago, but the national church never really grew and became well established. Then with the Khmer Rouge regime, the small national church was destroyed. Only four pastors survived and most of the Christians either fled to the camps in Thailand or died under the Khmer Rouge.

Realistically, the national church in Cambodia is a new pioneer work. The majority of us here are working with first-generation believers. Therefore, the idea of pioneering is more appropriate to Cambodia when compared to the rest of the world, since Cambodia has experienced such a terrible past. *This is a pioneer field and not a mature field. We need to understand that to accurately set our strategies and plans.*

## Parent Stage

As growth continues, we see new life springing up from the seed of the Word—babes in Christ requiring great care and attention. As with physical infants, these new believers require constant attention from their parents or teachers. This work of nurturing depends totally upon the mission for sustenance; the national church is in the learning stage. This stage requires the gift of teaching from the missionary. The young national church has a growing child's relationship to the mission. The missionaries must "parent" without being "paternalistic." This means they must guide, instruct, teach, model, and apply God's Word in culturally appropriate ways, but must not view the national church or its members as "children to be bossed around" or "employees to be ordered around." Many of the five-to-ten-year-old ministries in Cambodia are entering this stage. They are trying to disciple new believers in such basic issues as church attendance, personal devotions, prayer, and Bible reading. Though many new churches are developing materials to facilitate this growth, there remains a vast need for more basic discipleship resources.

In helping plant two churches I have experienced the conflict that arises in moving from Pioneer to Parent stage. It is the

# Parent Stage

**Positives:**

- ✓ **Growth is rapid with solid teaching**
- ✓ **Genuine change in lives beginning**
- ✓ **Most opportune time to build lasting relationships (parent without being paternalistic)**

**Negatives:**

- ✓ **Early stages require the church to be totally dependant upon the mission**
- ✓ **Conflicts arise as church grows**
- ✓ **Without trusting relationships failure is imminent**




age-old tension between the "evangelist" wanting more people to have opportunity to respond to the Gospel message and the "pastor" who wants to bolt the door shut, recognizing he cannot properly care for the people he already has. We must recognize that in these stages of growth sometimes we "grow out," and other times we let our roots "grow down." One is not more important than the other. They simply represent different stages of growth.

I believe some of the Cambodian pastors have experienced this transition too. Remember when your church was small and all the time you put into evangelism and going to new houses and villages with the Gospel? Then a day came when you had thirty to forty people coming regularly. They began sharing their problems and wanting you to come counsel them. You saw the need to better train them and teach them the Word of God, but your habit was to go out witnessing and not stay at the church and counsel people. A tension arose—that tension is the transition between these two stages. You need to recognize this and grow. Don't make the mistake of continuing to pioneer and not parent. You will bring them in the front door, but if you don't care for them they will leave

out the back door just as fast. Why do we have churches that continue to attract new members, yet whose attendance remains the same? Because they are not parenting the infants they bear.

**Partnership Stage**

The next stage is a very difficult transition for both the missionary and the local church. It could be compared to having teenagers in your home. They are not really children, as they are big and physically developed; yet they are not quite adults, as they have so little practical experience. The teenage son wants to be a man. He is willing to "prove" how strong or tough he is. He is like a young rooster strutting around and crowing. The father wants to "let him go" and gain experience, but it is hard when the father knows the pain and long term effects one poor decision can make.

# Partnership Stage

**Positives:**

- ✓ **Strength of national church emerging**
- ✓ **Creativity and cultural bridges being developed**
- ✓ **Vast new areas of ministry opening as greater human resources are available**

**Negatives:**

- ✓ **Most difficult transition (for both parties!)**
- ✓ **Cracks in the first two stages will show**
- ✓ **Most causalities occur now**




For the NGO this means turning over multi-million dollar programs, handing over the keys to vehicles and equipment, allowing the work to be governed by nationals, and allowing the nationals to make decisions that will affect the future of the NGO. This is not easy to do! Yet, some nationals believe they are ready

to do this within three to four years. "Let me show you how to do this right!" is the attitude of some. Oh, the pain involved in this transition . . . it is not an easy time.

Just as in our families, this transition is best prepared for when the relationship is young. We must build trust in one another and learn to appreciate one another's gifts and experiences. We must acknowledge early on that when the time for transition comes it will be painful. There is no easy way to do this; it takes the grace of God on both parts. Becoming equal with one another is something that opposes human nature. We both want to be in charge, but God is saying at this stage that one needs to let go and trust, while the other needs to respectfully take up the leadership role on a transitioning basis. The new leaders must start slow and gradually take full control. God will help us make this transition, but we certainly can make it less painful by being aware of what is happening.

## Participation Stage

Once the partnership stage has reached its climax, full control belongs to the nationals. The control of the denomination or NGO is now fully in their capable hands. The organization is being run with experience and wisdom. God is now blessing the nationals with growth and success.

At this stage the missionary needs to know when to move on to the next field. Not all missionaries are gifted for each stage of this developmental process. Strong Type A personalities often chafe under the vision, direction, and guidance of the national leaders. This is a recipe for continual conflict. Why do it? At this stage the local church or NGO needs to say, "We would like this one and that one to stay and work with us. But we need to see these others move on." At this stage the national church is in full control and they will only need the services of those highly specialized missionaries or technical experts. We will need missionaries with advanced theological training when we see true Bible colleges and seminaries in Cambodia, training at the master's level and higher. Do you believe that day will come? Yes, friends, it will. And we will need missionaries skilled in areas like television, radio, and

other mass media to help the national church develop the programs they want to produce. This does not mean there will not be Cambodian technicians. But these are examples of what it means to be in the Participant stage.

Local NGO's will need people helping in areas of specialized medicine, micro-finance, or other areas of expertise. The major decisions will at this stage be made by the Cambodian leaders, but we never want to isolate ourselves from the wisdom and experience of our Christian brothers and sisters.

## Participation Stage

**Positives:**

- ✓ Ultimate goal achieved!
- ✓ New People Groups being targeted by national church
- ✓ Most missionaries moving on to next unreached field

**Negatives:**

- ✓ Some "old timers" hanging on
- ✓ Politicking among national leaders for supreme control




### Conclusion

There you have it—the four P's of relationship development between missionaries and nationals. This model is given in the hope that by understanding the process we can improve our relationships with one another. And remember, don't be so foolish as to compare your church or organization with another. There is no value in this—it will only breed jealousy or anger.

I would challenge each of you to go back and talk with those you are working with and see where you think you are at on this developmental process. It might be enlightening to see that one

person thinks we are pioneering while another thinks we are in the participation stage!

Once you determine where you currently are, talk about the future. How do you want to get to the next stage? How long do you think it will take? What will be the signs that you are growing into that next stage?

Taking the time to answer all of these questions will help us build strong relationships between missionaries and nationals.

---

This material was presented at the 2001 General Assembly of the Evangelical Fellowship of Cambodia in Phnom Penh.

សំណុំឯកឃ្លុំ ២/៣ (កក្កដា ២០០១)៖ ៣១-៤៥



លោក វ៉េស លីនឃ្វីស្ត

# ទំនាក់ទំនងរវាងក្រុមជំនុំជាតិ និង បេសកជន

### ដំណាក់ការនៃការលូតលាស់

## សេចក្តីផ្តើម

នៅពេលដែលយើងនិយាយពីការធ្វើការជាមួយគ្នា គឺយើងកំពុងតែនិយាយពីទំនាក់ទំនង ។ នៅគម្ពីរយ៉ូហាន ១៧ ព្រះយេស៊ូបានបង្រៀនថា លោកិយគេនឹងបានដឹងថា យើងជាសិស្សរបស់ព្រះអង្គ ដោយសារតែទំនាក់ទំនងរបស់យើង ។ បងប្អូនជនជាតិខ្មែរ តើបងប្អូនមានទំនាក់ទំនងល្អជាមួយនឹងបេសកជន ដែលបងប្អូនធ្វើការជាមួយគ្នានោះឬទេ? ចំណែកឯបេសកជន តើបងប្អូនមានទំនាក់ទំនងល្អជាមួយបងប្អូន ខ្មែរ ដែលបងប្អូនធ្វើការជាមួយឬទេ? គោលដៅនៃអត្ថបទនេះគឺ ជួយជំរុញឲ្យមានទំនាក់ទំនងឲ្យបានប្រសើរឡើង នៅក្នុងចំណោមយើង ។

## លំដាប់លំដោយនៃភាពជាដៃគូ

ទំនាក់ទំនង គឺដូចមានបង្ហាញនូវក្នុងរូបតាងដូចតទៅ ភាពជាដៃគូទាំងអស់ គឺកសាងឡើងដោយសារទំនាក់ទំនង ។ នេះគឺជាគ្រឹះដ៏រឹងមាំរបស់ក្រុមជាច្រើន អង្គការក្រៅរដ្ឋាភិបាលជាច្រើន ឬ អង្គការដទៃទៀត ។

បើគ្មានទំនាក់ទំនងរឹងមាំនោះទេ ភាពជាដៃគូរបស់យើងនឹងទៅទន់ខ្សោយ និង មិនស្ថិតស្ថេរនៅយូរអង្វែងឡើយ ។

<u>គោលបំណង:</u> គឺនៅពេលដែលទំនាក់ទំនងបានពង្រឹងឲ្យរឹងមាំឡើងនោះ យើងត្រូវការមានគោលបំណងច្បាស់លាស់ ។ ទំនាក់ទំនងដែលគ្មានគោលបំណងនោះ គឺគ្រាន់តែជាមិត្តសម្លាញ់ មួយក្រុមប៉ុណ្ណោះ ។ ចំពោះការធ្វើជាដៃគូនឹងគ្នានោះ យើងត្រូវមានគោលបំណងដែលយល់ព្រមទៅវិញទៅមក មានន័យថា គឺជាការអ្វីមួយ ដែលយើងទាំងពីរចង់ឲ្យបានសម្រេចទៅដល់គោលដៅ ។




<u>យុទ្ធសាស្ត្រ:</u> គឺនៅពេលដែលទំនាក់ទំនងរបស់យើងមាន ការយល់ព្រមគ្នាលើគោលបំណងមួយនោះ បន្ទាប់មកយើងត្រូវការកំណត់រកឲ្យឃើញនូវយុទ្ធសាស្ត្រ ។ តើយើងនឹងសម្រេចគោលបំណងរបស់យើងដោយរបៀបណា? នៅត្រង់នេះបទពិសោធន៍ និង ការហ្វឹកហ្វឺនគឺបង្ហាញចាប់ផ្តើមបង្ហាញពីផលចំរើនយ៉ាងសម្បើម ។

ធនធាន: ក្នុងនាមជាគ្រីស្ទបរិស័ទ ជំហានបន្ទាប់របស់យើងគឺត្រូវកំណត់រកឲ្យឃើញនូវធនធាន ដែលយើងត្រូវការ ដើម្បីបំពេញឲ្យបានសម្រេចនូវយុទ្ធសាស្ត្រ និង គោលបំណងរបស់យើង ដោយការអធិស្ឋានយ៉ាងអស់ពីចិត្ត ។ នៅក្នុងលោកិយនេះ យើងតែងតែចាប់ផ្ដើមធ្វើការដោយការមើលពីធនធាន ដែលយើងមានគឺ: "តើយើងមានលុយប៉ុន្មាន?" ប៉ុន្តែក្នុងនាមយើងជាគ្រីស្ទបរិស័ទ យើងត្រូវការស្វែងរកមើលពីគោលបំណង និង យុទ្ធសាស្ត្ររបស់ព្រះជាម្ចាស់ជាមុនសិន ។ បន្ទាប់មកទើបអធិស្ឋាន ដោយជំនឿសម្រាប់រកធនធាននោះ ។

ការងារ: គឺជាទីបញ្ចប់ ភាពជាដៃគូដែលយើងបានកសាងឡើងយ៉ាងរឹងមាំនៅលើទំនាក់ទំនងទាំងឡាយ ដែលបង្ហាញឲ្យឃើញពីគោលបំណង ដែលយល់ចិត្តគ្នាទៅវិញមក យុទ្ធសាស្ត្រវៃឆ្លាត និងការប៉ាន់ប្រមាណចាត់ចែងធនធាន អាចចាប់ផ្ដើមធ្វើការជាមួយគ្នា ។

លទ្ធផលនៃការពង្រឹងភាពជាដៃគូលើទំនាក់ទំនង ឲ្យរឹងមាំឡើងនោះគឺជាសមត្ថភាពធ្វើការថ្វាយព្រះដ៏ធំសម្បើម ។ មិនថាឡើយគេធ្វើការនៅក្នុងក្រុមជំនុំ ក្នុងអង្គការក្រៅរដ្ឋាភិបាល ឬ អង្គការគ្រីស្ទបរិស័ទដទៃទៀតនោះឡើយ កម្លាំងរឹងមាំរបស់អង្គការគឺ គេឃើញមាននៅក្នុងកម្លាំងនៃទំនាក់ទំនងរបស់គេ ។

## ចំណុចសំខាន់នៃទំនាក់ទំនង

អត្ថបទនេះ នឹងផ្ដោតការយកចិត្តទុកដាក់លើចំណុចមួយនៃគំរូខាងលើនេះ ។ ផ្នែកដ៏សំខាន់បំផុត តែងាយនឹងបែកបាក់នោះគឺ ជាទំនាក់ទំនងរបស់យើង ។ បងប្អូនប្រុសស្រីអើយ យើងអាចមានគោលបំណងប្រសើរបំផុត យុទ្ធសាស្ត្រល្អប្រណិត និង ធនធានមានច្រើនសន្ធឹក ប៉ុន្តែការងារ និង ភាពជាដៃគូរបស់យើងនឹងទៅជាគ្មានបានផលអ្វីឡើយ

បើសិនជាទំនាក់ទំនងរបស់យើងនោះបាក់បែកខ្ទេចខ្ទាំ ។ យើងត្រូវតែឲ្យអាទិភាពខ្ពស់លើទំនាក់ទំនងឲ្យបានច្រើនជាងការងាររបស់យើង ។ ព្រះយេស៊ូមិនបានសុគត ដោយព្រោះគម្រោងកម្មវិធីការងាររបស់យើងទេ តែព្រះអង្គសុគតដោយព្រោះព្រះអង្គស្រឡាញ់មនុស្ស ។ យើងត្រូវផ្ដល់ការថែទាំ និងយកចិត្តទុកដាក់ដល់មនុស្ស ឲ្យបានច្រើនជាងដល់ការយកចិត្តទុកដាក់ដល់ការងារ ។ អាទិភាពត្រូវចាប់ផ្ដើមពីមនុស្ស ដែលយើងធ្វើការជាមួយមិនមែនគ្រាន់តែជនរងគ្រោះ ឬ មនុស្សមានបាបដែលឈឺចាប់ ដែលគម្រោងកម្មវិធីរបស់យើងតែងតែផ្ដោតសំខាន់ចំពោះការងារនោះ ។

## ទំនាក់ទំនងគឺជាអាទិភាពរបស់យើង

ព្រះគ្រីស្ទមិនបានសុគតសម្រាប់

គម្រោងកម្មវិធីរបស់អ្នកទេ

ព្រះគ្រីស្ទបានសុគត

ដូច្នេះយើងអាចមានទំនាក់ទំនង

ល្អ



លោក រិន ធី ប្រើគំរូដែលមាន៤ដំណាក់ការសម្រាប់ធ្វើការងារតាមរយៈទំនាក់ទំនងរវាងក្រុមជំនុំជាតិ និង បេសកជន[១] ។ តម្លៃសំខាន់នៅ

[1] Ralph D. Winter and Steven C. Hawthorne, eds., *Perspectives on the World Christian Movement* (Pasadena: William Carey Library, 1981).

ក្នុងគំរូការងាររបស់គាត់គឺ ទទួលស្គាល់ថាគ្រប់ទំនាក់ទំនងទាំងអស់ត្រូវតែមានការប្តូរផ្លាស់ និង មានការរីកចំរើនឡើង ។ នេះគឺជាសញ្ញានៃការលូតលាស់ និង ការមានសុខភាពល្អ ។ តែទោះជាយ៉ាងណាក៏ដោយ ការមានភាពតានតឹងនៅជាមួយគ្នានោះដែរ ។ ការផ្លាស់ប្តូរតម្រូវឲ្យមានការរំកិលពីដំណាក់ការមួយទៅដំណាក់ការមួយទៀត ចំពោះគំរូនេះបណ្តាលឲ្យយើងមានភាពតានតឹងយ៉ាងសម្បើម ។ បើយើងនូវដំណាក់ការនៃទំនាក់ទំនងទាំងអស់នេះ យើងអាចយល់គ្នាបានប្រសើរឡើង និង ចូលរួមជាដៃគូគ្នាកាន់តែប្រសើរឡើយ ។ គឺជួយឲ្យយើងស្វែងរកនូវផ្លូវល្អ

## ដំណាក់ការទាំងបួននៃការលូតលាស់នៃទំនាក់ទំនង អ្នកក្នុងស្រុក និង បេសកជន

❶ ដំណាក់ការត្រួសត្រាយផ្លូវ

❷ ដំណាក់ការបីបាច់ថែរក្សា

❸ ដំណាក់ការធ្វើជាដៃគូ

❹ ដំណាក់ការចូលរួម




តាមរយៈការផ្លាស់ប្តូរ ដែលចំរើនលូតលាស់ ដ៏ប្រកបដោយភាពតានតឹង ។

ក្នុងនាមខ្ញុំជាបេសកជន ខ្ញុំនឹងចាប់ផ្ដើមនិយាយអំពីតួនាទីរបស់បេសកជន ។ គឺជាតួនាទី ដែលមានការវិវឌ្ឍន៍ទៅមុខរហូតគឺ ដូចនឹងគ្រូបង្រៀនម្នាក់ ដែលបានបង្រៀនដល់សិស្ស ហើយបន្ទាប់មកហ្វឹកហ្វឺនសិស្សនោះក្លាយទៅជាគ្រូបង្រៀន ហើយក្រោយមកទីបំផុត បានក្លាយជានិយោជិកនៅក្នុងសាលារៀន ។

ជួនកាលយើងប្រើការប្រៀបធៀបរវាងឪពុកម្ដាយ និង កូន ដើម្បីពណ៌នាពីការចំរើនលូតលាស់ក្នុងផ្នែកទំនាក់ទំនងនេះ ។ បងប្អូនបេសកជនទាំងឡាយ មិនត្រូវរក្សានូវការគ្រប់គ្រងលើការងារក្នុងស្រុករហូតនោះឡើយ ឬក៏មិនត្រូវព្រលែងការងារឲ្យអ្នកក្នុងស្រុកឆាប់ពេកដែរ ។ គឺដូចគ្នាដែរនឹងរបស់មានជីវិតទាំងឡាយ គឺត្រូវមានដំណើរការនៃការលូតលាស់ និង ការរីកចំរើនធំឡើងតាមបែបធម្មជាតិ ។ គ្មានឪពុកម្ដាយណាចង់បញ្ចុកបាយ និង ងូតទឹកឲ្យកូនអាយុ ២០ ឆ្នាំ ហើយនោះឡើយ ។ **ទំនាក់ទំនងរបស់បេសកជន ត្រូវតែឆ្លុះមើលពីគំរូនៃការលូតលាស់តាមបែបធម្មជាតិ ។**

**ការយល់ដឹងពីគំរូនេះ អនុញ្ញាតឲ្យយើងមើលឃើញថា តួនាទី និង ទំនាក់ទំនងរបស់យើង នឹងផ្លាស់ប្ដូរនៅពេលណាមួយ ។ នៅពេលដែលយើងមានការរីកចំរើនពេញវ័យ ជាក្រុមជំនុំក្នុងស្រុក យើងនឹងឆ្លងកាត់នូវដំណាក់ការទាំង ៤ យ៉ាងនេះ ។ ការសំខាន់ដែលយើងត្រូវចងចាំនោះគឺថា អង្គការ និង និកាយនិមួយៗ មានសន្ទុះនៃការបោះជំហាននោះ**ខុសៗគ្នា ។ គឺគ្មានវិធីសាស្ត្រណា "ត្រឹមត្រូវ" ឬ ក៏មិនមាន "ល្បឿនមានលក្ខណៈដូចគ្នា" ណាមួយ ដែលទំនាក់ទំនងទាំងអស់នេះត្រូវធ្វើតាមឡើយ ។ គឺដូចគ្នា នឹងកូនរបស់យើងដែរកូនខ្លះ ក៏វាធំលឿនជាងកូនដទៃ ។

ពាក្យមួយម៉ាត់ ដែលយើងប្រុងប្រយ័ត្ន នៅក្នុង ២ កូរិនថូស ១០:១២ បានព្រមានយើងពីភាព "ល្ងង់ល្ងើ" នៃការដែលយើងប្រៀបផ្ទឹម

គ្នាយើងនៅក្នុងចំណោមគ្នាយើង ។ សកម្មភាពមួយក្នុងចំណោមសកម្មភាពទាំងឡាយ ដែលគ្រោះថ្នាក់បំផុត គឺការដែលយើងអាចជាប់ជំពាក់វាក់វិននោះ គឺការប្រៀបធៀបពីការខុសប្លែកគ្នា ដែលបេសកជន និង អ្នកនៅក្នុងស្រុកអភិវឌ្ឍទំនាក់ទំនងរបស់ខ្លួន ។ ដូចគ្នាដែរ នឹងវត្ថុមានជីវិតទាំងឡាយ ការលូតលាស់អាចកើតឡើងបាន គឺអាស្រ័យលើល័ក្ខណ្ឌនៃការផ្តល់អាហារ ទឹក ការថែបំប៉ន និង ការថែរក្សាចំលក្ខណៈនោះឯង ។ "ដី" ឬ បុគ្គលិកលក្ខណៈរបស់មនុស្ស គឺជាប់ទាក់ទងក្នុងផ្នែកសំខាន់នៃការចំរើនលូតលាស់ ។ ខ្ញុំធុញថប់ក្នុងការបោសសំអាតពាក្យខ្លះដូចជា "បេសកជនទាំងអស់មកដាក់អាណានិគម និង ចង់គ្រប់គ្រង" ឬ "អ្នកក្នុងស្រុកទាំងអស់សុទ្ធតែ មិនបានទទួលការអប់រំផ្នែក ព្រះគម្ពីរបានត្រឹមត្រូវ និង សុទ្ធតែលោភចង់បានប្រាក់ និង អំណាច ។" គ្មានមូលដ្ឋានជាក់លាក់ណាមួយ ក្នុងការធ្វើការថ្លែងសេចក្តីបែបហ្នឹងឡើយ ហើយទំនាក់ទំនងដ៏ពិតប្រាកដ នឹងមិនត្រូវបង្កើតឲ្យមានបរិយាកាស ដ៏មិនគួរឲ្យស្និតបែបនោះឡើយ ។

## ជំហាក់ការត្រួសត្រាយផ្លូវ

ហេតុផលគឺថាជារឿយៗ យើងត្រូវការអ្នកត្រួសត្រាយផ្លូវ មាននិមិត្តរឹងមាំ ។ ពួកអ្នកត្រួសត្រាយផ្លូវតែងមានបុគ្គលិកលក្ខណៈរឹងមាំ និង មានលក្ខណៈគ្រប់គ្រងពីលើ ។ មនុស្សបែបនេះ និង មិនព្រមឲ្យមានអ្វីមករារាំងចំពោះការនាំពន្លឺនៃដំណឹងល្អ ដើម្បីជួយបំភ្លឺដល់ព្រលឹងមនុស្សដែលកំពុងជាប់ក្នុងសេចក្តីងងឹតនោះឡើយ ។ មនុស្សមានលក្ខណៈរឹងមាំដោយមានគំនិតម៉ឺងម៉ាត់ ។ ចូរក្រឡេកមើលទៅពួកគេមួយភ្លែតហើយអ្នកអាចឃើញថាគេព្រមនេះបង់សេរីភាព និងសិទ្ធិរបស់ខ្លួន ដោយព្រោះតែចង់ជួយអ្នកដទៃ ហើយក្រឡេកមើលពួកគេមួយភ្លែតទៀត អ្នកអាចឃើញថា គេមុជក្បាលចុះនៅក្នុងទំនាក់ទំនង និងខ្វះការសម្រេចបាន

ល្អត្រឹមត្រូវ ។ មនុស្សទាំងនេះខ្លាំងដូចក្របី មានន័យថា បើកម្លាំងរបស់គេបានដឹកនាំតាមទិសដៅត្រឹមត្រូវគេអាចធ្វើឲ្យបានទទួលផលប្រយោជន៍យ៉ាងសម្បើម ។ ប៉ុន្តែបើកម្លាំងរបស់គេបានដឹកនាំខុសគេធ្វើឲ្យមានបញ្ហាយ៉ាងច្រើនសម្បើម ។

នៅពេលបច្ចុប្បន្ននេះ មានតែ ០.៦% នៃចំនួនប្រជារាស្ត្រកម្ពុជាប៉ុណ្ណោះ ដែលជាអ្នកជឿដល់ព្រះគ្រីស្ទ ។ ដូច្នេះ យើងមិនត្រូវការបេសកជន ដែលជាអ្នកត្រួសត្រាយផ្លូវ ធ្វើមិនដឹងមិនឮអំពីហេតុការណ៍នេះឡើយ ។

## ដំណាក់ការត្រួសត្រាយផ្លូវ

ចំណុចវិជ្ជមាន:

- ✓ បុគ្គលិកលក្ខណៈឯករាជ្យរឹងប៉ឹង
- ✓ នឹងធ្វើការលះបង់យ៉ាងសម្បើម ដើម្បីចង់ឃើញអ្នកដទៃបានឮដំណឹងល្អ ។
- ✓ចាប់ផ្តើមធ្វើការងារដោយខ្លួនឯង
- ✓ មានទំនាស់តិចតួច ដោយហេតុថាគ្មាននរណាម្នាក់ទៀត ដើម្បីឈ្លោះនោះឡើយ ។

ចំណុចអវិជ្ជមាន:

- ✓ បុគ្គលិកលក្ខណៈឯករាជ្យរឹងប៉ឹង
- ✓ ហាក់បីដូចមានចំណុចមើលឃើញតែមួយជ្រុង
- ✓ ប្រឈមមុខគគាំងជានិច្ច



mission
*បេសកកម្ម*

ចំពោះការដែលខ្ញុំដឹង ស្ទើរតែគ្រប់ខេត្តទាំង ២១ យ៉ាងហោចណាស់មានការប្រជុំតាមផ្ទះ ឬ ព្រះវិហារគ្រីស្តបរិស័ទមួយកន្លែង ហើយក៏មានព្រះវិហារគ្រីស្តបរិស័ទមួយកន្លែងនៅគ្រប់ទាំង ៤ នោះដែរ ។

ប៉ុន្តែ តើក្នុងចំណោម ១៧៣ ស្រុក ឬ ៣៦០០០ ភូមិ នោះមានស្នាបន្ទាល់គ្រីស្តបរិស័ទប៉ុន្មានដែរ? ភាគច្រើនមិនមានការធ្វើបន្ទាល់ពីព្រះ

គ្រីស្ទសោះឡើយ! នេះគឺជាប្រទេស ដែលត្រូវការបេសកជន ដែលជាអ្នកត្រួសត្រាយផ្លូវយ៉ាងខ្លាំង ។ ខ្ញុំកាន់តែហ៊ានជំរុញ ក្រុមជំនុំជាតិដែលកំពុងមានការរីកចំរើនផុលផុស ឲ្យផ្ដោតនូវការប្រើធនធានរបស់ខ្លួនចំពោះការត្រួសត្រាយផ្លូវ សម្រាប់ស្រុក និង ភូមិថ្មីៗទាំងឡាយនោះ ឲ្យគេបានស្គាល់ព្រះគ្រីស្ទដែរ ។

នៅក្នុងដំណាក់ការត្រួសត្រាយផ្លូវ នៃការងារបេសកកម្មនៅពេលបច្ចុប្បន្ននេះ នៅក្នុងប្រទេសកម្ពុជា ជនបរទេសជាច្រើនកំពុងយល់ច្រឡំដោយការប្រកែកដូចជាថា "សម័យអាណានិគមនៃការត្រួសត្រាយផ្លូវគឺបានចប់សព្វគ្រប់ហើយ ។ ឥឡូវនេះ យើងត្រូវជួយពង្រឹង និង បំពាក់បំប៉នដល់ក្រុមជំនុំជាតិ" ។ ការប្រកែកមួយបែបទៀត ដែលថា "ក្រុមជំនុំជាតិ (ក្នុងស្រុក) អាចធ្វើការបានប្រសើរ ដោយព្រោះគេចេះភាសា និង ទំនៀមទម្លាប់របស់គេ ហើយតាមពិតទៅចុះសោហ៊ុយតិចទៀតផង" ។ តែទោះជាយ៉ាងណាក៏ដោយអស់អ្នក ដែលជំទាស់តាមរបៀបនេះ មិនបានដឹងថា ភាពប្រាកដនិយមបែបនោះ ចេញមកពីប្រជាជាតិនានា កាលពីជាង ២០០ ឆ្នាំ នៃប្រវត្តិសាស្ត្ររបស់បេសកកម្ម ។ មានរបៀបមួយ ដែលគេតែងតែប្រើយ៉ាងច្រើន នៅពេលបច្ចុប្បន្ននេះ នៅទូទាំងពិភពលោក នោះគឺថា "ប្រទេសកំពុងអភិវឌ្ឍន៍" ឬ "តតិយលោក" កំពុងតែចាប់ផ្ដើមបញ្ជូនបេសកជនឲ្យចេញទៅក្រៅប្រទេសខ្លួន ។

នៅក្នុងស្រុកខ្មែរ យើងឃើញផលផ្លែ ដែលបានកើតឡើងដោយបេសកជនមកពី ហ្វីលីពីន កូរ៉េ និង មកពីប្រទេសថៃ ។ ប្រទេសដែលបានបញ្ជូនបេសកជនចេញទាំងនោះ បានទទួលនូវការរីកចំរើននៃក្រុមជំនុំជាតិជាង ១៥០, ១០០ និង ៨០ ឆ្នាំ តាមប្រទេសរៀងៗខ្លួន ។ ចូរយើងប្រៀបធៀបប្រទេសទាំងនេះទៅនឹងប្រទេសកម្ពុជា ។ មែនហើយប្រទេសកម្ពុជា មានបេសកជនប្រតេស្តង់ជាលើកដំបូង ជិត ៨០ ឆ្នាំកន្លងមកហើយ ប៉ុន្តែក្រុមជំនុំជាតិមិនដែលបានលូតលាស់ និង បានរីង

មាំឡើយ ។ បន្ទាប់ក្រោយមក ដោយសាររបបខ្មែរក្រហម ក្រុមជំនុំជាតិដ៏ក្មេងខ្ចីត្រូវរលាយសាបសូន្យ ។ មានតែគ្រូគង្វាល ៨ នាក់ ប៉ុណ្ណោះ ដែលនៅរស់រាន មានជីវិតនោះ និង គ្រីស្ទបរិស័ទ ភាគច្រើន រត់ចូលនៅក្នុងជំរំនៅក្នុងទឹកដីថៃ ឬ ក៏ស្លាប់នៅក្រោមរបបខ្មែរក្រហម ។

តាមពិតទៅ ក្រុមជំនុំជាតិ នៅក្នុងប្រទេសកម្ពុជា គឺជាការងារត្រួសត្រាយផ្លូវថ្មីមួយ ។ ពួកយើងភាគច្រើននៅទីនេះធ្វើការជាមួយ អ្នកជឿជំនាន់ទី ១ ហេតុដូច្នេះហើយ គំនិតដែលថាជាការត្រួសត្រាយផ្លូវនៅគឺសក្តិសមណាស់ ចំពោះប្រទេសកម្ពុជា នៅពេលដែលយើងប្រៀបទៅនឹងប្រទេសដទៃនៅលើសកលលោកនេះ ដោយហេតុថា ប្រទេសកម្ពុជាទទួលរងនូវរឿងគួរឲ្យរន្ធត់កាលពីអតីតកាលនោះ ។ នេះជាវាលថ្មី ដែលត្រូវត្រួសត្រាយ និងមិនមែនជាវាលដែលគេត្រួសត្រាយហើយនោះទេ ។ យើងត្រូវយល់ចំពោះស្ថានភាពនោះ ដើម្បីឲ្យយើងដាក់យុទ្ធសាស្ត្រ និងផែនការរបស់យើងឲ្យបានត្រឹមត្រូវល្អ ។

## ដំណាក់ការបីច្បាច់ថែរក្សា

នៅពេលដែលមានការរីកចំរើន ជាបន្តនោះ យើងឃើញជីវិតថ្មីមួយបានផុសឡើង ពីគ្រាប់ពូជនៃព្រះបន្ទូល គឺមានន័យថាទារកនៅក្នុងព្រះគ្រីស្ទនោះ ត្រូវការនូវការថែទាំ និង ការយកចិត្តទុកដាក់យ៉ាងខ្លាំងសម្បើមណាស់ ។ ដូចគ្នានឹងទារក ទើបនឹងកើតដែរ អ្នកជឿថ្មីទាំងអស់នេះត្រូវការយកចិត្តទុកដាក់ ពីអ្នកបង្កើតគេមក ឬ ពីគ្រូរបស់គេ ។ ការងារនៃការថែបំប៉ននេះ អាស្រ័យទាំងស្រុងលើបេសកកម្ម ចំពោះការផ្តល់នូវការគាំពារ ដល់ក្រុមជំនុំជាតិ ដែលនៅក្នុងដំណាក់ការនៃការរៀនសូត្រ ។ នៅក្នុងដំណាក់ការនេះ តម្រូវឲ្យមាននូវអំណោយទាននៃការបង្រៀនពីបេសកជន ។ ក្រុមជំនុំជាតិនៅក្មេងខ្ចី មានការចំរើនលូតលាស់ទំនាក់ទំនងរបស់កូនក្មេង ទៅនឹងបេសកកម្ម ។ ពួកបេសកជន ត្រូវតែ

"បីបាច់ថែរក្សា" ដោយមិនចាំបាច់ធ្វើជាលក្ខណៈ "គ្រប់គ្រង" នោះឡើយ ។ គឺបានសេចក្តីថា គេត្រូវតែដឹកនាំ បង្ហាត់បង្រៀន ធ្វើជាគំរូ និងប្រើព្រះបន្ទូលរបស់ព្រះឲ្យស៊ីនឹងទំនៀមទម្លាប់ ប៉ុន្តែមិនត្រូវមើលទៅក្រុមជំនុំជាតិ ឬ សមាជិករបស់ក្រុមជំនុំនោះ ដូចជា "កូនក្មេង ដែលត្រូវឲ្យធ្វើជាចៅហ្វាយ" ឬ "បញ្ជាទៅក្រុមជំនុំប្រៀបជាបុគ្គលិក" នោះឡើយ ។ ព័ន្ធកិច្ចជាច្រើន ដែលមានអាយុពី ៥ ទៅ ១០ ឆ្នាំ នៅក្នុងស្រុកខ្មែរ កំពុងតែ

## ដំណាក់ការបីបាច់ថែរក្សា

ចំណុចវិជ្ជមាន:

- ✓ ការលូតលាស់យ៉ាងលឿនដោយមានការបង្រៀនច្បាស់លាស់
- ✓ ចាប់ផ្តើមមានការផ្លាស់ប្តូរនៅក្នុងជីវិតពិតប្រាកដ
- ✓ មានពេលជាច្រើនដើម្បីពង្រឹងទំនាក់ទំនងដ៏យូរអង្វែង(ក្នុងឋានៈជាអ្នកថែរក្សាមិនមែនជាអ្នកគ្រប់គ្រង) ។

ចំណុចអវិជ្ជមាន:

- ✓ ដំណាក់ការដំបូងតម្រូវឲ្យក្រុមជំនុំពឹងផ្អែកទាំងស្រុងលើបេសកកម្ម ។
- ✓ ទំនាស់នឹងកើតឡើងនៅពេលដែលពួកជំនុំចំរើនឡើង ។
- ✓ បរាជ័យនៃទំនាក់ទំនង ដែលមិនទុកចិត្តគ្នា កាន់តែកៀកឡើងៗ ។




បោះជំហានចូលទៅក្នុងដំណាក់ការនេះ ។ ព័ន្ធកិច្ចទាំងនោះកំពុងតែព្យាយាម បង្កើតសិស្សដល់អ្នកជឿថ្មី តាមបែបមួយជាមូលដ្ឋានមែនទែន ដូចជាការគិតពីចំនួនចូលរួមប្រជុំនៅក្នុងព្រះវិហារ ការចូលគាល់ព្រះ តាមរយៈព្រះបន្ទូលការអធិស្ឋាន និងការអានព្រះគម្ពីរ ។ ថ្វីដ្បិតតែមានក្រុមជំនុំថ្មី ជាច្រើនកំពុងបង្កើតសម្ភារៈផ្សេងៗ ដើម្បីជួយសម្រួលដល់ការលូតលាស់នេះក៏ដោយចុះ ក៏នៅតែមានសេចក្តីត្រូវការយ៉ាងច្រើនថែមទៀត ផ្នែកធនធានបង្កើតសិស្ស ។

នៅក្នុងការជួយបង្កើតក្រុមជំនុំពីរកន្លែង ខ្ញុំមានបទពិសោធន៍ចំពោះទំនាស់ ដែលកើតឡើង នៅក្នុងពេលឆ្លងពីដំណាក់ការគ្រួសព្រោយ ទៅដល់ដំណាក់ការបីបាច់ថែរក្សា ។ គឺជាភាពតានតឹងដ៏យូរលង់មកហើយ រវាង "អ្នកផ្សាយដំណឹងល្អ" ដែលចង់បានឲ្យមានមនុស្សជាច្រើនមានឱកាសទទួលព្រះរាជសារដំណឹងល្អ និង "គ្រូគង្វាល" ដែលចង់ចាក់គន្លឹះទ្វារបិទ មិនចង់ទទួលមនុស្សច្រើន ដោយទទួលស្គាល់ថា គាត់មិនអាចថែទាំមនុស្សទាំងឡាយ ដែលគាត់មានរួចហើយនោះមិនបានល្អត្រឹមត្រូវ ។ យើងត្រូវព្រមទទួលស្គាល់ថា នៅក្នុងដំណាក់ការនៃការលូតលាស់ទាំងឡាយនេះ ជួនកាលយើង "លូតលាស់ធំពេក" និង ពេលខ្លះទៀត យើងទុកឲ្យឫសរបស់យើង "ចាក់ឫសឲ្យជ្រៅ" ។ គ្មានមួយណាប្រសើរជាងមួយណាឡើយ ។ គ្រាន់តែពួកគេបង្ហាញនូវភាពខុសគ្នានៃដំណាក់ការនៃការលូតលាស់តែប៉ុណ្ណោះ ។

ខ្ញុំជឿថា គ្រូគង្វាលខ្មែរខ្លះ ក៏មានបទពិសោធន៍ចំពោះដំណាក់ការផ្លាស់ប្តូរនេះដែរ ។ ចូរចងចាំ នៅពេលដែលក្រុមជំនុំរបស់លោកអ្នក នៅតូចនៅឡើយ លោកអ្នកតែងតែចំណាយពេលគ្រប់ពេលក្នុងការផ្សាយដំណឹងល្អពីផ្ទះមួយ ទៅផ្ទះមួយពីភូមិមួយទៅភូមិមួយ ។ ស្រាប់តែដល់ពេលមួយ លោកអ្នកមានសមាជិកមកថ្វាយបង្គំទៀងទាត់ ពី ៣០ នាក់ ទៅ ៤០ នាក់ នោះ ។ គេចាប់ផ្តើមប្រាប់ពីបញ្ហារបស់គេ និង គេចង់ឲ្យលោកអ្នកចុះទៅផ្តល់ការប្រឹក្សាឲ្យឱវាទដល់ពួកគេ ។ លោកអ្នកបានឃើញសេចក្តីត្រូវការ ដែលហ្វឹកហ្វឺនគេឲ្យបានល្អប្រសើរឡើង និង បង្រៀនគេឲ្យចេះព្រះបន្ទូល ប៉ុន្តែទម្លាប់របស់លោកអ្នក គឺត្រូវចេញទៅផ្សាយដំណឹងល្អ មិនមែននៅក្នុងព្រះវិហារ ដើម្បីជួយផ្តល់ការប្រឹក្សាឲ្យឱវាទនោះឡើយ ។ ភាពតានតឹងក៏កើតមានឡើង គឺមានន័យថាភាពតានតឹងនៃការផ្លេរប្តូររវាងដំណាក់ការទាំងពីរនេះ ។ លោកអ្នកត្រូវទទួលស្គាល់ការនេះ និងត្រូវចេះលូតលាស់ឡើង ។ ចូរកុំគិតតែពីគ្រួសព្រោយ

តែរហូត មិនបានឈានចូលដំណាក់ការបីបាច់ថែរក្សានោះឡើយ ។ លោកអ្នកនាំគេមកដល់ទ្វារមុខ តែបើមិនបានយកចិត្តទុកដាក់ក្នុងការថែទាំគេនោះទេ គេចេញតាមទ្វារក្រោយយ៉ាងរហ័សបំផុត ។ ហេតុអ្វីបានជាយើងនៅតែមានក្រុមជំនុំ ដែលនៅតែបន្តទាក់ទាញដល់ចិត្តសមាជិកជឿថ្មី តែចំនួនមកព្រះវិហារហាក់ដូចជានៅដដែល? ពីព្រោះក្រុមជំនុំនោះមិនបានបីបាច់ថែរក្សាទារក ដែលខ្លួនបានបង្កើតមកនោះឲ្យបានល្អ ។

## ដំណាក់ការធ្វើជាដៃគូ

ដំណាក់ការបន្ទាប់ គឺជាការផ្លាស់ប្តូរដ៏លំបាកបំផុត សម្រាប់បេសកជន និង ក្រុមជំនុំក្នុងស្រុក ។ ការនោះគឺអាចប្រៀបធៀបការ ដែលយើងមានក្មេងជំទង់នៅក្នុងផ្ទះរបស់លោកអ្នកដែរ ។ គេមិនមែនជាកូនក្មេងទៀតទេ នៅពេលដែលគេធំឡើង និង រាងកាយគេធំចម្រើនឡើង តែគេមិនទាន់ក្លាយជាមនុស្សពេញវ័យនៅឡើយទេ ព្រោះគេមានបទពិសោធន៍នៃការអនុវត្តន៍ជាក់ស្តែង ។ កូនប្រុសដែលនៅជំទង់នោះ គេចង់ក្លាយទៅជាបុរសពេញវ័យ ។ គាត់តែងតែ "បង្ហាញ" ថារឹងប៉ឹង ឬ មុតមាំហើយ ។ គាត់ប្រៀបដូចជាមាន់ជល់ ដែលទើបតែនឹងពកខ្លាយ ដើរត្រាំងចុះត្រាំងឡើង និង រងាវបង្អួតដាក់គេឯង ។ ឪពុកចង់ "ព្រលែងឲ្យកូនទៅ" ដើម្បីឲ្យបានទទួលនូវបទពិសោធន៍កើនឡើង ប៉ុន្តែគឺយ៉ាប់ណាស់ ដែលឪពុកដឹងថានឹងមានការឈឺចាប់ និង មានឥទ្ធិពលប៉ះពាល់ដ៏យូរអង្វែង ដោយព្រោះតែការធ្វើការសម្រេចណាមួយ ដែលមិនបានគិតវែងឆ្ងាយ ។

ចំពោះអង្គការក្រៅរដ្ឋាភិបាលវិញ ចំណុចនេះគឺមានន័យថា ផ្នែរកម្មវិធី ដែលមានលុយរាប់លានដុល្លារ ហុចកូនសោរឡាន និង សម្ភារៈទាំងឡាយ អនុញ្ញាតឲ្យអ្នកម្ចាស់ស្រុកធ្វើការសម្រេច ដែលនឹងមានឥទ្ធិពលប៉ះពាល់ដល់អនាគតរបស់អង្គការក្រៅរដ្ឋាភិបាលនោះ ។ មិនមែនជាការងាយស្រួលធ្វើឡើយ ! តែមានអ្នកម្ចាស់ស្រុកខ្លះជឿថា គេត្រៀមរួចជា

## ដំណាក់ការនៃការធ្វើជាដៃគូ

ចំណុចវិជ្ជមាន:

- ✓ កម្លាំងរឹងមាំនៃក្រុមជំនុំជាតិលេចធ្លោឡើង
- ✓ ប្រាជ្ញាញាណនិងការធ្វើស្ពានចម្លងផ្នែកវប្បធម៌ បានកើតមានឡើង ។
- ✓ សកម្មភាពថ្មីដ៏ធំធេងនៃការបើកចំហឲ្យមានព័ន្ធកិច្ចនៅតាមកន្លែងផ្សេងៗ ដោយមានធនធានមនុស្សកើនឡើងច្រើន ។

ចំណុចអវិជ្ជមាន:

- ✓ មានការពិបាកបំផុតក្នុងការផ្ទេរ(សម្រាប់ភាគីទាំងពីរ)
- ✓ ស្នាមប្រេះនឹងឃើញមាននៅក្នុងដំណាក់ការពីរដំបូង
- ✓ មានអ្នករងរបួសយ៉ាងច្រើនកើតឡើងឥឡូវនេះ




ស្រេចហើយ ដើម្បីធ្វើកិច្ចការនេះក្នុងអំឡុងពេលពីបីទៅបួនឆ្នាំនោះ ។ “ទុកឲ្យខ្ញុំបង្ហាញអ្នកនូវរបៀបធ្វើឲ្យបានត្រឹមត្រូវ !” អ្នកខ្លះមានគំនិតបែបហ្នឹង ។ អូ ! មានការឈឺចាប់នៅពេលផ្ទេរការងារនេះ . . . គឺមិនមែនជាពេល ដែលងាយស្រួលឡើយ ។

ដូចគ្នានៅក្នុងគ្រួសាររបស់យើងដែរ ការងារផ្ទេរនេះគឺត្រូវរៀបចំឲ្យបានប្រសើរបំផុត នៅពេលដែលទំនាក់ទំនងនៅវ័យក្មេងនោះ ។ យើងត្រូវបង្កើននូវការទុកចិត្តគ្នា និង រៀនទទួលពីអំណោយទាន និង បទពិសោធន៍ពីគ្នាទៅវិញទៅមក ។ យើងត្រូវទទួលស្គាល់ឲ្យបានដឹងពីខាងដើមថា នៅពេលដែលផ្ទេរការងារនេះ គឺនឹងមានការឈឺចាប់ ។ ការផ្លូវណា ដែលងាយស្រួល ដើម្បីធ្វើការងារនេះឡើយ គឺត្រូវការព្រះគុណរបស់ព្រះជាម្ចាស់ ចំពោះផ្នែកទាំងពីរនេះ ។ ការក្លាយទៅជាមានភាពស្មើគ្នាជាមួយនរណាម្នាក់នោះ គឺជារឿងមួយ ដែលប្រឆាំងនឹងនិស្ស័យលក្ខណៈពីធម្មជាតិរបស់មនុស្ស ។ យើងទាំងពីរ ចង់ធ្វើជាអ្នកទទួលខុស

ត្រូវ តែព្រះជាម្ចាស់កំពុងមានបន្ទូលថា នៅក្នុងដំណាក់ការនេះ គឺត្រូវព្រលែង និង ត្រូវទុកចិត្ត ឯម្នាក់ទៀតត្រូវព្រមទទួលតាមតួនាទីនៃការដឹកនាំនៅលើជំហាននៃការផ្ទេរការងារនោះដោយគោរព ។ អ្នកដឹកនាំថ្មី ត្រូវចាប់ផ្តើមយឺតៗ និង បន្តិចម្តងៗ ទើបទទួលយកនូវការគ្រប់គ្រង ត្រួតត្រាទាំងស្រុង ។ ព្រះជាម្ចាស់នឹងជួយឲ្យយើងអាចធ្វើការផ្ទេរនេះបាន ប៉ុន្តែយើងពិតជាអាចកាត់បន្ថយនូវការឈឺចាប់នេះបាន ដោយបានដឹងជាមុនថានឹងមានអ្វីកើតឡើង ។

## ដំណាក់ការចូលរួម

នៅពេលដែលដំណាក់ការ នៃការចូលរួមបានឡើងដល់ចំណុចកំពូលរបស់វា ការគ្រប់គ្រងទាំងស្រុងនោះ គឺត្រូវជាអ្នកម្ចាស់ស្រុក ។ ការគ្រប់គ្រងនៃនិកាយ ឬ អង្គការក្រៅរដ្ឋាភិបាល ឥឡូវនេះស្ថិតនៅក្នុងដៃរបស់ដ៏មានសមត្ថភាពរបស់គេ ។ អង្គការនោះ គឺចាត់ចែងដោយប្រើបទពិសោធន៍ និង ប្រាជ្ញា ។ ឥឡូវនេះព្រះជាម្ចាស់ប្រទានពរ ដល់អ្នកម្ចាស់ស្រុក ដោយមានការរីកចំរើន និង ទទួលជោគជ័យ ។

នៅក្នុងដំណាក់ការនេះ បេសកជនត្រូវដឹងថា ដល់ពេលដែលខ្លួនត្រូវរើទៅកន្លែងផ្សេងទៀតហើយ ។ មិនមែនបេសកជនទាំងអស់សុទ្ធតែមានអំណោយទានចំពោះដំណាក់ការនីមួយៗនៃដំណើរការអភិវឌ្ឍន៍នោះឡើយ ។ ផ្នែករឹងមាំនៃបុគ្គលលក្ខណៈនោះ តែងតែមានការឃ្ដើសចិត្ត នៅពេលដែលអ្នកដឹកនាំក្នុងស្រុក ផ្តល់និម្មិត ការបង្ហាញទិសដៅ និង ការដឹកនាំនោះ ។ នេះគឺជាគ្រឿងផ្សំមួយ ដែលបន្តទំនាស់រហូតមក ។ ហេតុអ្វីបានជាធ្វើការនេះ? នៅដំណាក់ការនេះ គឺក្រុមជំនុំក្នុងស្រុក ឬ អង្គការក្រៅរដ្ឋាភិបាល ត្រូវនិយាយថា "យើងចង់បានឲ្យដំណាក់ការមួយនេះ និង មួយនោះ នៅធ្វើការជាមួយយើង ។ ប៉ុន្តែយើងត្រូវឲ្យចំណុចដទៃទាំងឡាយនោះផ្លាស់ចេញ ។" នៅត្រង់ដំណាក់ការនេះ ក្រុមជំនុំជាតិ គ្រប់

គ្រងពេញទី គឺគេគ្រាន់តែត្រូវការសេវកម្មពីបេសកជនទាំងឡាយ ដែលមានបច្ចេកទេសពិសេស ឬ ជំនាញពិសេសតែប៉ុណ្ណោះ ។ យើងត្រូវការបេសកជន ដែលមានការហ្វឹកហ្វឺនជាន់ខ្ពស់ ផ្នែកទេវសាស្ត្រ នៅពេលដែលយើងចង់ឃើញសាលាព្រះគម្ពីរ និង សិក្ខាសាលាជាន់ខ្ពស់ នៅក្នុងស្រុកខ្មែរ គឺការហ្វឹកហ្វឺនជាន់ខ្ពស់ថ្នាក់បរិញ្ញា និង ខ្ពស់ជាងនេះទៅ

## ដំណាក់ការនៃការចូលរួម

ចំណុចវិជ្ជមានៈ

- ✓ បានសម្រេចនូវទិសដៅផ្ដាច់ព្រ័ត្រ
- ✓ ក្រុមជំនុំជាតិជាអ្នកដៅក្រុមមនុស្សថ្មី
- ✓ បេសកជនភាគច្រើនផ្លាស់ទៅកន្លែងដែលមិនពួជំណើងល្អថ្មីទៀត ។

ចំណុចអវិជ្ជមានៈ

- ✓ អ្នកធ្វើការ "ចាស់ៗខ្លះ" មិនចង់ព្រលែងដៃ ។
- ✓ ល្បិចនយោបាយមាននៅក្នុងចំណោមអ្នកដឹកនាំម្ចាស់ស្រុក ដោយព្រោះចង់កាន់អំណាចគ្រប់គ្រង ។



church
ក្រុមជំនុំ

mission
បេសកកម្ម

ទៀត ។ តើលោកអ្នកជឿថា ថ្ងៃនោះនឹងមកដល់នោះមែន ។ យើងនឹងត្រូវការបេសកជន ដែលមានជំនាញផ្នែក ទូរទស្សន៍ វិទ្យុ និង ផ្នែកផ្សព្វផ្សាយដទៃទៀត ដើម្បីឲ្យក្រុមជំនុំក្នុងស្រុក ផលិតកម្មវិធីទាំងឡាយដែលគេចង់ផលិតឡើងនោះ ។ ការនេះមិនមែនមានន័យថា គ្មានអ្នកបច្ចេកទេស ដែលជាជាតិខ្មែរនោះឡើយ ។ តែទាំងនេះគឺជា គំរូទាំងឡាយ ដែលមានន័យថា ការនៅក្នុងដំណាក់ការចូលរួម ។

អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកត្រូវការមនុស្សជួយខាងឯកទេស ឱសថ ហិរញ្ញវត្ថុ ឬ ផ្នែកជំនាញដទៃទៀត ។ ការសម្រេចចិត្តសំខាន់ៗនៅក្នុងដំណាក់ការនេះ អ្នកដឹកនាំខ្មែរគឺជាអ្នកសម្រេច ប៉ុន្តែយើងមិនចង់ញែកខ្លួនយើងឲ្យដាច់ចេញពីគតិបណ្ឌិត និង បទពិសោធន៍របស់បងប្អូនប្រុសស្រីគ្រីស្ទបរិស័ទរបស់យើងនោះដែរ ។

## សរុបសេចក្តី

លោកអ្នកមាន ៤ ចំណុចនៃការរីកចំរើន នៃទំនាក់ទំនងរវាងបេសកជន និង អ្នកនៅក្នុងស្រុក ។ គំរូនេះគឺផ្តល់ជូន ដោយមានសេចក្តីសង្ឃឹមថា មានការយល់ដឹងនូវដំណើរការ ដែលយើងអាចធ្វើឲ្យទំនាក់ទំនងរបស់យើងជាមួយគ្នាបានប្រសើរឡើង ។ ចូរចងចាំ កុំឲ្យយើងប្រព្រឹត្តដោយឥតប្រាជ្ញា ដោយសារការប្រៀបធៀបក្រុមជំនុំ ឬ អង្គការរបស់យើង ជាមួយអ្នកដទៃទៀត ។ គឺគ្មានគុណតម្លៃអ្វីឡើយ នៅក្នុងការងារប្រៀបធៀបបែបនោះ គឺមានតែនាំឲ្យមានការច្រណែន ឬ ខឹងសម្បារតែប៉ុណ្ណោះ ។

ខ្ញុំចង់ជំរុញលើកទឹកចិត្ត ដល់លោកអ្នក ឲ្យត្រឡប់ទៅនិយាយជាមួយអស់អ្នកដែលលោកអ្នកធ្វើការជាមួយ ហើយពិចារណាមើល តើលោកអ្នកកំពុងនៅក្នុងដំណាក់ការនៃដំណើរការអភិវឌ្ឍន៍ នៃទំនាក់ទំនងនេះ ។ គឺប្រហែលជាអាច បំភ្លឺឲ្យឃើញថាម្នាក់គិតថា យើងកំពុងស្ថិតនៅក្នុងដំណាក់ការនៃការត្រួសត្រាយផ្លូវ ឯម្នាក់ទៀតគិតថា យើងកំពុងនៅក្នុងដំណាក់ការនៃការចូលរួម !

នៅពេលដែលលោកអ្នក កំណត់រកឲ្យឃើញថា លោកអ្នកកំពុងនៅត្រង់ណាឥឡូវនេះ ចូរនិយាយពីអនាគត ។ តើយើងចង់ធ្វើរបៀបម៉េចនៅក្នុងដំណាក់ការបន្ទាប់? តើលោកអ្នកគិតថា វាត្រូវចំណាយពេល

ប៉ុន្មាន? តើអ្វីទៅដែលជាសញ្ញាបង្ហាញថា លោកអ្នកកំពុងរីកលូតលាស់ទៅក្នុងដំណាក់ការបន្ទាប់ទៀតនោះ ?

ការចំណាយពេលឆ្លើយនូវសំណួរទាំងឡាយនេះ នឹងជួយឲ្យយើងពង្រឹងទំនាក់ទំនងរបស់យើង រវាងបេសកជន និង អ្នកម្ចាស់ស្រុក ។

---

*មេរៀននេះបានបង្រៀនទៅពេលសន្និបាតប្រចាំ ២០០១ របស់ប្រិយសម្ព័ន្ធគ្រីស្ទបរិស័ទកម្ពុជា នៅទីក្រុងភ្នំពេញ ។*